ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

សំណុំរឿងរដ្ឋប្បវេណីលេខ: ១៤៩
ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤
សាលក្រមលេខ: ០២៥/ជ
ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្តាល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤ ដោយមានសមាសភាពដូចខាងក្រោម៖

**ចៅក្រមជំនុំជម្រះ**

លោក[redacted]ចៅក្រមសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

លោក[redacted]ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

-ដើមចោទឈ្មោះ[redacted]មួយគា ភេទស្រី អាយុ៤០ឆ្នាំ សញ្ជាតិខ្មែរ [redacted]

មានមេធាវី [redacted]តំណាងដោយអាណត្តិឱ្យ

-ចុងចម្លើយ: គ្មាន

អង្គហេតុ និងចំណុចវិវាទ

១-សាលក្រមដែលទាមទារដោយដើមចោទ

ដើមចោទប្តឹងសុំឱ្យតុលាការចេញសាលក្រមបញ្ជាក់ថា ឈ្មោះ [redacted]ចន្ទាវី ភេទស្រី កើតនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៨៣ មានទីកន្លែងកំណើត[redacted]ដែលមានឪពុកឈ្មោះ[redacted]ភាព និងម្តាយឈ្មោះ [redacted]សុខា និងឈ្មោះ [redacted]មួយគា ភេទស្រី ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៣ មានទីកន្លែងកំណើតស្ថិតនៅ[redacted] មានឪពុកឈ្មោះ[redacted]ភាព និងម្តាយឈ្មោះ[redacted]សុខា ជាមនុស្សតែម្នាក់ និងសុំប្រើប្រាស់ឈ្មោះ[redacted]មួយគា ភេទស្រី ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៣ មានទីកន្លែងកំណើតស្ថិតនៅ[redacted]។

២-ការពន្យល់ត្រួសៗអំពីរឿងក្តី

រឿងក្តីនេះ ជារឿងក្តីដែលដើមចោទប្តឹងសុំឱ្យតុលាការចេញសាលក្រមបញ្ជាក់ថា ឈ្មោះ [redacted] ចន្ទាវី កើតនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៨៣ មានទីកន្លែងកំណើត [redacted] ដែលមានឪពុកឈ្មោះ[redacted]ភាព និងម្តាយឈ្មោះ [redacted]សុខា និងឈ្មោះ [redacted]មួយគា ភេទស្រី ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៣ មានទីកន្លែងកំណើតស្ថិតនៅ[redacted] មានឪពុកឈ្មោះ[redacted]ភាព និងម្តាយឈ្មោះ [redacted] សុខា ជាមនុស្សតែម្នាក់ និងសុំប្រើប្រាស់ឈ្មោះ [redacted] មួយគា ភេទស្រី ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៣ មានទីកន្លែងកំណើតស្ថិតនៅ[redacted] ជាផ្លូវការ ដោយសារតាំងពីកើតមករហូតមកដល់ឆ្នាំ២០០០ ដើមចោទប្រើប្រាស់ឈ្មោះ[redacted]ចន្ទាវី កើតនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៨៣ មានទីកន្លែងកំណើត [redacted] ដែលមានឪពុកឈ្មោះ [redacted] ភាព និងម្តាយឈ្មោះ[redacted]សុខា ហើយឪពុកម្តាយរបស់ដើមចោទ បានដាក់ឈ្មោះឱ្យដើមចោទនៅសម័យនោះឈ្មោះ [redacted]ចន្ទាវី តែពួកគាត់មិនបានចុះបញ្ជីបញ្ជាក់កំណើតឱ្យដើមចោទទេ។ នៅឆ្នាំ១៩៨៨ ឪពុកម្តាយរបស់ដើមចោទក៏បានឱ្យដើមចោទចូលរៀននៅសាលាបឋមសិក្សា ដោយប្រើឈ្មោះសម្គាល់សិស្សថា

Scanned with CamScanner

[redacted]ចន្ទារី និងបានបន្តរៀនរហូតដល់អំឡុងឆ្នាំ១៩៩៩ ដើមចោទក៏បានប្រលងជាប់សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ និងទទួលបានវិញ្ញាបនប័ត្របណ្តោះអាសន្នមធ្យមសិក្សាបឋមភូមិលេខ៥៦-៣១ អយកភ-ចទម ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៩ ដោយប្រើឈ្មោះ [redacted] ចន្ទារី និងបានបន្តចូលរៀនថ្នាក់កម្រិតបរិញ្ញាបត្រវិទ្យាសាស្ត្រសេដ្ឋកិច្ច (បសក) នៅសកលវិទ្យាល័យ អាយ អាយ ស៊ី នៃបច្ចេកវិទ្យា ជំនាញ ហិរញ្ញវត្ថុ និងធនាគារ ហើយបានទទួលសញ្ញាបត្របរិញ្ញាបត្រ និងស្នើសុំចេញសញ្ញាបត្រទុតិយតា ឈ្មោះ [redacted] ចន្ទារី ជាថ្មីម្តងទៀង ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣។ តែនៅអំឡុងឆ្នាំ២០០០ ដោយសារតែដើមចោទជាកូនកាត់ខ្មែរចិន ហើយកាន់ព្រះពុទ្ធសាសនា ក៏មានជំនឿតាមបែបជូនតា នៃរបៀបក្បួនខ្មែរបុរាណ ហើយម្តាយរបស់ដើមចោទ បានសង្កេតឃើញថា ដើមចោទចេះតែមានជម្ងឺមិនចេះស្រាកស្រាន ហើយម៉្យាងវិញទៀត នៅក្នុងក្រុមគ្រួសារចេះតែមានរឿងរ៉ាវឈ្លោះប្រកែកគ្នា ទាស់សម្តីគ្នានៅក្នុងក្រុមគ្រួសារហូត ដូច្នេះទើបឪពុកម្តាយរបស់ដើមចោទសម្រេចប្តូរឈ្មោះដើមចោទពី[redacted]ចន្ទារី មកជាឈ្មោះ [redacted] មួយគា វិញ ដូចមានឈ្មោះក្នុងសេចក្តីចម្លងសំបុត្រកំណើត ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣ និងអត្តសញ្ញណប័ណ្ណសញ្ជាតិខ្មែរ លេខ ០១១០០២៧២៦ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៥ របស់ដើមចោទឈ្មោះ [redacted] មួយគា។ លុះក្រោយមកទៀត នៅអំឡុងឆ្នាំ២០១៥ ដើមចោទដែលមានឈ្មោះ [redacted]មួយគា ក៏បានរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ [redacted] គង់ម៉ុង ដោយមានសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៧ រវាងឈ្មោះ [redacted] គង់ម៉ុង និងដើមចោទឈ្មោះ ខាន់ មួយគា ហើយមានកូនចំនួន០២ (ពីរ) នាក់ កូនទី១ ឈ្មោះ លី ភិនយ៉ាសិលាមុនី ភេទស្រី កើតថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ និងកូនទី២ ឈ្មោះ [redacted] រិទ្ធីភាព្យ កើតថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨។ បច្ចុប្បន្នដោយហេតុថា ដើមចោទជាបុគ្គលដែលស្រលាញ់ការសិក្សារៀនសូត្រ ហើយដើមចោទមានបំណងចង់រៀនបន្តកម្រិតថ្នាក់អនុបណ្ឌិត នៅមហាវិទ្យាល័យ និងចង់ប្រើឈ្មោះក្នុងសញ្ញាបត្រកម្រិតថ្នាក់អនុបណ្ឌិត ដែលទទួលបាននាថ្ងៃអនាគតនោះ អោយមានឈ្មោះ [redacted] មួយគា ដែលជាឈ្មោះប្រើប្រាស់ជាផ្លូវការបច្ចុប្បន្ន ដូចមានឈ្មោះក្នុងសេចក្តីចម្លងសំបុត្រកំណើត អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ សៀវភៅគ្រួសារ និងឯកសារជាផ្លូវការផ្សេងៗទៀតជាដើម។ ហេតុដូចច្នេះហើយ ទើបដើមចោទដាក់ពាក្យបណ្តឹងសុំឱ្យតុលាការចេញសាលក្រមបញ្ជាក់ថា ឈ្មោះ [redacted]ន្ទារី កើតនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៨៣ មានទីកន្លែងកំណើត [redacted] ដែលមានឪពុកឈ្មោះ [redacted]ភាព និងម្តាយឈ្មោះ [redacted]សុខា និងឈ្មោះ [redacted]មួយគា ភេទស្រី ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៣ មានទីកន្លែងកំណើតស្ថិតនៅឃុំ[redacted] មានឪពុកឈ្មោះ [redacted] ភាព និងម្តាយឈ្មោះ [redacted] សុខា ជាមនុស្សតែម្នាក់ និងសុំប្រើប្រាស់ឈ្មោះ [redacted] មួយគា ភេទស្រី ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៣ មានទីកន្លែងកំណើតស្ថិត[redacted]ជាផ្លូវការ។

៣-ចំណុចវិវាទ និងចំណុចគ្មានវិវាទ

៣-១ ចំណុចវិវាទ

តើឈ្មោះ [redacted] ចន្ទារី កើតនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៨៣ មានទីកន្លែងកំណើត [redacted]ដែលមានឪពុកឈ្មោះ[redacted]ភាព និងម្តាយឈ្មោះ[redacted] សុខា និងឈ្មោះ[redacted]មួយគា ភេទស្រី ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៣ មានទីកន្លែងកំណើតស្ថិត[redacted]មានឪពុកឈ្មោះ[redacted]ភាព និងម្តាយឈ្មោះ [redacted] សុខា ជាមនុស្សតែម្នាក់?

៣-២ ចំណុចគ្មានវិវាទ: គ្មាន។

Scanned with CamScanner

៤-ការអះអាងរបស់ដើមចោទ

-ដើមចោទអះអាងនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថា ខ្លួនស្នើសុំឱ្យតុលាការចេញសាលក្រមបញ្ជាក់ថា ឈ្មោះ[redacted] ចន្ថាវី ភេទស្រី កើតនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៨៣ មានទីកន្លែងកំណើត [redacted] ដែលមានឪពុកឈ្មោះ[redacted]ភាព និងម្តាយឈ្មោះ[redacted] សុខា និងឈ្មោះ [redacted] មួយគា ភេទស្រី ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៣ មានទីកន្លែងកំណើតស្ថិត[redacted] មានឪពុកឈ្មោះ [redacted]ភាព និងម្តាយឈ្មោះ [redacted] សុខា ជាមនុស្សតែម្នាក់ និងសុំប្រើប្រាស់ឈ្មោះ[redacted] មួយគា ភេទស្រី ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៣ មានទីកន្លែងកំណើតស្ថិតនៅ[redacted]

ដោយសារតាំងពីកើតមករហូតមកដល់ឆ្នាំ២០០០ ខ្លួនប្រើប្រាស់ឈ្មោះ[redacted] ចន្ថាវី កើតនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៨៣ មានទីកន្លែងកំណើត [redacted] ដែលមានឪពុកឈ្មោះ [redacted] ភាព និងម្តាយឈ្មោះ [redacted] សុខា ហើយឪពុកម្តាយរបស់ខ្លួន បានដាក់ឈ្មោះឱ្យខ្លួននៅសម័យនោះឈ្មោះ[redacted] ចន្ថាវី តែពួកគាត់មិនបានចុះបញ្ជីបញ្ជាក់កំណើតឱ្យខ្លួនទេ។

នៅឆ្នាំ១៩៨៨ ឪពុកម្តាយរបស់ខ្លួនក៏បានឱ្យខ្លួនចូលរៀននៅសាលាបឋមសិក្សា ដោយប្រើឈ្មោះសម្គាល់សិស្សថា [redacted] ចន្ថាវី និងបានបន្តរៀនរហូតដល់អំឡុងឆ្នាំ១៩៩៩ ខ្លួនក៏បានប្រលងជាប់សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ និងទទួលបានវិញ្ញាបនប័ត្របណ្តោះអាសន្នមធ្យមសិក្សាបឋមភូមិលេខ៥៦-៣១អយកភ-ចទម ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៩ ដោយប្រើឈ្មោះ[redacted] ចន្ថាវី និងបានបន្តចូលរៀនថ្នាក់កម្រិតបរិញ្ញាបត្រវិទ្យាសាស្ត្រសេដ្ឋកិច្ច (បសក) នៅសកលវិទ្យាល័យ អាយ អាយ ស៊ី នៃបច្ចេកវិទ្យា ជំនាញ ហិរញ្ញវត្ថុ និងធនាគារ ហើយបានទទួលសញ្ញាបត្របរិញ្ញាបត្រ និងស្នើសុំចេញសញ្ញាបត្រទុតិយតា ឈ្មោះ [redacted] ចន្ថាវី ជាថ្មីម្តងទៀង ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣។

តែនៅអំឡុងឆ្នាំ២០០០ ដោយសារតែខ្លួនជាកូនកាត់ខ្មែរចិន ហើយកាន់ព្រះពុទ្ធសាសនា ក៏មានជំនឿតាមបែបដូនតានៃរបៀបក្បួនខ្មែរបុរាណ ហើយម្តាយរបស់ខ្លួន បានសង្កេតឃើញថា ខ្លួនចេះតែមានជម្ងឺមិនចេះស្រាកស្រាន ហើយម្យ៉ាងវិញទៀត នៅក្នុងក្រុមគ្រួសារចេះតែមានរឿងរ៉ាវឈ្លោះប្រកែកគ្នា ទាស់សម្តីគ្នានៅក្នុងក្រុមគ្រួសាររហូត ដូច្នេះទើបឪពុកម្តាយរបស់ខ្លួនសម្រេចប្តូរឈ្មោះខ្លួនពី [redacted] ចន្ថាវី មកជាឈ្មោះ[redacted] មួយគាវិញ ដូចមានឈ្មោះក្នុងសេចក្តីចម្លងសំបុត្រកំណើត ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣ និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១១០០២៧២៦ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៥ របស់ខ្លួនឈ្មោះ[redacted]មួយគា។

លុះក្រោយមកទៀតនៅអំឡុងឆ្នាំ២០១៥ ខ្លួនដែលមានឈ្មោះ [redacted]មួយគា ក៏បានរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ[redacted] គង់ម៉ិង ដោយមានសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៧ រវាងឈ្មោះ [redacted]គង់ម៉ិង និងខ្លួនឈ្មោះ[redacted]មួយគា ហើយមានកូនចំនួន០២ (ពីរ) នាក់ កូនទី១ ឈ្មោះ [redacted] ភិនយ៉ា សិលាមុនី ភេទស្រី កើតថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ និងកូនទី២ ឈ្មោះ លី រិទ្ធីរាជ្យ កើតថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨។

បច្ចុប្បន្នដោយហេតុថា ខ្លួនជាបុគ្គលដែលស្រលាញ់ការសិក្សារៀនសូត្រ ហើយខ្លួនមានបំណងចង់រៀនបន្តកម្រិតថ្នាក់អនុបណ្ឌិតនៅមហាវិទ្យាល័យ និងចង់ប្រើឈ្មោះក្នុងសញ្ញាបត្រកម្រិតថ្នាក់អនុបណ្ឌិត ដែលទទួលបាននាថ្ងៃអនាគតនោះ អោយមានឈ្មោះ [redacted] មួយគា ដែលជាឈ្មោះប្រើប្រាស់ជាផ្លូវការបច្ចុប្បន្ន ដូចមានឈ្មោះក្នុងសេចក្តីចម្លងសំបុត្រកំណើត អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ សៀវភៅគ្រួសារ និងឯកសារជាផ្លូវការផ្សេងៗទៀតជាដើម។

Scanned with CamScanner

ហេតុដូចច្នេះហើយ ទើបខ្លួនដាក់ពាក្យបណ្តឹងសុំឱ្យតុលាការចេញសាលក្រមបញ្ជាក់ថា ឈ្មោះ [redacted] ចន្ថាវី កើតនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៨៣ មានទីកន្លែងកំណើត [redacted] ដែលមានឪពុកឈ្មោះ [redacted] ភាព និងម្តាយឈ្មោះ [redacted] សុខា និងឈ្មោះ [redacted] មួយគា ភេទស្រី ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៣ មានទីកន្លែងកំណើតស្ថិតនៅ [redacted] មានឪពុកឈ្មោះ [redacted] ភាព និងម្តាយឈ្មោះ [redacted] សុខា ជាមនុស្សតែម្នាក់ និងសុំប្រើប្រាស់ឈ្មោះ [redacted] មួយគា ភេទស្រី ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៣ មានទីកន្លែងកំណើតស្ថិតនៅ [redacted]។

-ដើមចោទធ្វើសេចក្តីអះអាងនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ថា ខ្លួនសុំធ្វើសេចក្តីថ្លែងការណ៍ពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថា ខ្លួនប្តឹងទាមទារ និងអះអាងដូចក្នុងកំណត់ហេតុនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល កាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៤ រក្សាទុកនៅទាំងស្រុង។

## **សំអាងហេតុ**

១-ដើមចោទអះអាងថា ខ្លួនស្នើសុំឱ្យតុលាការចេញសាលក្រមបញ្ជាក់ថា ឈ្មោះ [redacted] ចន្ថាវី ភេទស្រី កើតនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៨៣ មានទីកន្លែងកំណើត [redacted] ដែលមានឪពុកឈ្មោះ [redacted] ភាព និងម្តាយឈ្មោះ [redacted] សុខា និងឈ្មោះ [redacted] មួយគា ភេទស្រី ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៣ មានទីកន្លែងកំណើតស្ថិតនៅ [redacted] មានឪពុកឈ្មោះ [redacted] ភាព និងម្តាយឈ្មោះ [redacted] សុខា ជាមនុស្សតែម្នាក់ និងសុំប្រើប្រាស់ឈ្មោះ [redacted] មួយគា ភេទស្រី ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៣ មានទីកន្លែងកំណើតស្ថិតនៅ [redacted] ជាផ្លូវការ ដោយសារតាំងពីកើតមកហូតមកដល់ឆ្នាំ២០០០ ខ្លួនប្រើប្រាស់ឈ្មោះ [redacted] ចន្ថាវី កើតនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៨៣ មានទីកន្លែងកំណើត [redacted] ដែលមានឪពុកឈ្មោះ [redacted] ភាព និងម្តាយឈ្មោះ [redacted] សុខា ហើយឪពុកម្តាយរបស់ខ្លួន បានដាក់ឈ្មោះឱ្យខ្លួននៅសម័យនោះឈ្មោះ [redacted] ចន្ថាវី តែពួកគាត់មិនបានចុះបញ្ជីបញ្ជាក់កំណើតឱ្យខ្លួនទេ។ នៅឆ្នាំ១៩៨៨ ឪពុកម្តាយរបស់ខ្លួនក៏បានឱ្យខ្លួនចូលរៀននៅសាលាបឋមសិក្សា ដោយប្រើឈ្មោះសម្គាល់សិស្សថា [redacted] ចន្ថាវី និងបានបន្តរៀនរហូតដល់អំឡុងឆ្នាំ១៩៩៩ ខ្លួនក៏បានប្រលងជាប់សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ និងទទួលបានវិញ្ញាបនប័ត្របណ្តោះអាសន្នមធ្យមសិក្សាបឋមភូមិលេខ៥៦-៣១អយកភ-ចទម ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៩ ដោយប្រើឈ្មោះ [redacted] ចន្ថាវី និងបានបន្តចូលរៀនថ្នាក់កម្រិតបរិញ្ញាបត្រវិទ្យាសាស្ត្រសេដ្ឋកិច្ច (បសក) នៅសកលវិទ្យាល័យ អាយ អាយ ស៊ី នៃបច្ចេកវិទ្យា ជំនាញ ហិរញ្ញវត្ថុ និងធនាគារ ហើយបានទទួលសញ្ញាបត្របរិញ្ញាបត្រ និងស្នើសុំចេញសញ្ញាបត្រទុតិយតា ឈ្មោះ [redacted] ចន្ថាវី ជាថ្មីម្តងទៀត ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣។ តែនៅអំឡុងឆ្នាំ២០០០ ដោយសារតែខ្លួនជាកូនកាត់ខ្មែរចិន ហើយកាន់ព្រះពុទ្ធសាសនា ក៏មានជំនឿតាមបែបដូនតានៃរបៀបក្បួនខ្មែរបុរាណ ហើយម្តាយរបស់ខ្លួន បានសង្កេតឃើញថា ខ្លួនចេះតែមានជម្ងឺមិនចេះស្រាកស្រាន ហើយម៉្យាងវិញទៀត នៅក្នុងក្រុមគ្រួសារចេះតែមានរឿងរ៉ាវឈ្លោះប្រកែកគ្នា ទាស់សម្តីគ្នានៅក្នុងក្រុមគ្រួសារហូត ដូច្នេះទើបឪពុកម្តាយរបស់ខ្លួនសម្រេចប្តូរឈ្មោះខ្លួនពី [redacted] ចន្ថាវី មកជាឈ្មោះ [redacted] មួយគា វិញ ដូចមានឈ្មោះក្នុងសេចក្តីចម្លងសំបុត្រកំណើត ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣ និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១១០០២៧២៦ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៥ របស់ខ្លួនឈ្មោះ [redacted] មួយគា។ លុះក្រោយមកទៀតនៅអំឡុងឆ្នាំ២០១៥ ខ្លួនដែលមានឈ្មោះ ខាន់ មួយគា ក៏បានរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ [redacted] គង់ម៉ិង ដោយមានសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៧ រវាងឈ្មោះ [redacted] គង់ម៉ិង និងខ្លួនឈ្មោះ [redacted] មួយគា ហើយមានកូនចំនួន០២ (ពីរ) នាក់ កូនទី១ ឈ្មោះ [redacted] ភិនយ៉ាសិលាមុនី ភេទ

Scanned with CamScanner

ស្រី កើតថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ និងកូនទី២ ឈ្មោះ [redacted] រិទ្ធីរាជ្យ កើតថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨។ បច្ចុប្បន្នដោយហេតុថា ខ្លួនជាបុគ្គលដែលស្រលាញ់ការសិក្សារៀនសូត្រ ហើយខ្លួនមានបំណងចង់រៀនបន្តកម្រិតថ្នាក់អនុបណ្ឌិតនៅមហាវិទ្យាល័យ និងចង់ប្រើឈ្មោះក្នុងសញ្ញាបត្រកម្រិតថ្នាក់អនុបណ្ឌិត ដែលទទួលបាននាថ្ងៃអនាគតនោះ អោយមានឈ្មោះ [redacted] មួយគា ដែលជាឈ្មោះប្រើប្រាស់ជាផ្លូវការបច្ចុប្បន្ន ដូចមានឈ្មោះក្នុងសេចក្ដីចម្លងសំបុត្រកំណើត អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍ សៀវភៅគ្រួសារ និងឯកសារជាផ្លូវការផ្សេងៗទៀតជាដើម។ ហេតុដូចច្នេះហើយ ទើបខ្លួនដាក់ពាក្យបណ្ដឹងសុំឱ្យតុលាការចេញសាលក្រមបញ្ជាក់ថា ឈ្មោះ [redacted] ចន្ថាវី កើតនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៨៣ មានទីកន្លែង[redacted] ដែលមានឪពុកឈ្មោះ [redacted] ភាព និងម្ដាយឈ្មោះ [redacted] សុខា និងឈ្មោះ [redacted] មួយគា ភេទស្រី ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៣ មានទីកន្លែងកំណើតស្ថិតនៅឃុំ [redacted] មានឪពុកឈ្មោះ [redacted] ភាព និងម្ដាយឈ្មោះ [redacted] សុខា ជាមនុស្សតែម្នាក់ និងសុំប្រើប្រាស់ឈ្មោះ [redacted] មួយគា ភេទស្រី ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៣ មានទីកន្លែងកំណើតស្ថិតនៅ[redacted]។

២-យោងតាមការអះអាងរបស់ដើមចោទ កាតសម្គាល់សិស្ស ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៩ វិញ្ញាបនប័ត្របណ្ដោះអាសន្នមធ្យមសិក្សាបឋមភូមិលេខ ៥៦-៣១ អយកក-ចទម ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៩ និងសញ្ញាបត្របរិញ្ញាបត្រ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣ គឺពិតជាសរសេរឈ្មោះ ថ្ងៃខែឆ្នាំកំណើត និងទីកន្លែងកំណើតរបស់ដើមចោទ **"ឈ្មោះ [redacted] ចន្ថាវី ភេទស្រី កើតថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៨៣** [redacted] និងឪពុកម្ដាយរបស់ដើមចោទឈ្មោះ **"ឪពុកឈ្មោះ [redacted] សុភាព ម្ដាយឈ្មោះ [redacted] សុខា"** ប្រាកដមែន។

៣-យោងតាមការអះអាងរបស់ដើមចោទ សេចក្ដីចម្លងសំបុត្របញ្ជាក់កំណើត ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣ ចេញដោយមន្ត្រីអត្រានុគោលដ្ឋានសង្កាត់អូឡាំពិក សេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៧ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់តាក្ដុល សេចក្ដីចម្លងសំបុត្របញ្ជាក់កំណើត ចុះថ្ងៃទី២១ខែឧសភា ឆ្នាំ២០១៨ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់តាក្ដុល សេចក្ដីចម្លងសំបុត្របញ្ជាក់កំណើត ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២០ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានតាក្ដុល និងសៀវភៅគ្រួសារលេខ ០១.១៦៩៨៦ ក.ណ គឺពិតជាសរសេរឈ្មោះ ថ្ងៃខែឆ្នាំកំណើត និងទីកន្លែងកំណើតរបស់ដើមចោទ **"ឈ្មោះ [redacted] មួយគា កើតថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៣"** កើត[redacted]ប្រាកដមែន។

៤-យោងតាមការអះអាងរបស់ដើមចោទ និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ០១១០០២៧២៦ មានសុពលភាពដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥ គឺពិតជាសរសេរឈ្មោះ និងថ្ងៃខែឆ្នាំកំណើតរបស់ដើមចោទ **"ឈ្មោះ [redacted] មួយគា កើតថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៣"** និងទីកន្លែងកំណើត "[redacted]" ប្រាកដមែន។

៥-យោងតាមលិខិតបញ្ជាក់លេខ១២៤៧/២៣ ស.ដម ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៣ របស់ចៅសង្កាត់ដើមមៀន បញ្ជាក់ថា ឈ្មោះ [redacted] ចន្ថាវី ភេទស្រី កើតថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៨៣ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីកន្លែងកំណើត [redacted] ឪពុកឈ្មោះ [redacted] ភាព (រស់) កើតថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ១៩៥១ ម្ដាយឈ្មោះ [redacted] សុខា (រស់) កើតថ្ងៃទី០៥ ខែមីនា ឆ្នាំ១៩៥៧ និងឈ្មោះ [redacted] មួយគា ភេទស្រី កើតថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៣ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីកន្លែងកំណើត [redacted] ឪពុកឈ្មោះ [redacted] ភាព (រស់) កើតថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ១៩៥១ ម្ដាយឈ្មោះ [redacted] សុខា (រស់) កើតថ្ងៃទី០៥ ខែមីនា ឆ្នាំ១៩៥៧ ជាមនុស្សតែម្នាក់ ហើយសូមប្រើប្រាស់ឈ្មោះ [redacted] មួយគា ភេទស្រី

Scanned with CamScanner

២០ ខែកក្កដា ឆ្នាំ១៩៨៣ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីកន្លែងកំណើត [redacted] ឳពុកឈ្មោះ[redacted]ភាព (រស់) កើតថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ១៩៥១ ម្តាយឈ្មោះ [redacted] សុខា (រស់) កើតថ្ងៃទី០៥ ខែមីនា ឆ្នាំ១៩៥៧ ជាផ្លូវការប្រាកដមែន។

៦-យោងតាមចំណុចទី១, ២, ៣, ៤ និងចំណុចទី៥ នៃសំអាងហេតុនេះ ដើមចោទប្តឹងសុំឱ្យតុលាការចេញសាលក្រមបញ្ជាក់ថា ឈ្មោះ [redacted]ចន្ថាវី ភេទស្រី កើតនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៨៣ មានទីកន្លែងកំណើត [redacted] ដែលមានឳពុកឈ្មោះ [redacted]ភាព និងម្តាយឈ្មោះ [redacted] សុខា និងឈ្មោះ[redacted] មួយគា ភេទស្រី ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៣ មានទីកន្លែងកំណើតស្ថិតនៅឃុំ [redacted]មានឳពុកឈ្មោះ[redacted] ភាព និងម្តាយឈ្មោះ [redacted] សុខា ជាមនុស្សតែម្នាក់ និងសុំប្រើប្រាស់ឈ្មោះ [redacted] មួយគា ភេទស្រី ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៣ មានទីកន្លែងកំណើតស្ថិតនៅ[redacted] ជាផ្លូវការ មានលក្ខណៈត្រឹមត្រូវ គប្បីសម្រេចតាមការទាមទាររបស់ដើមចោទ។

៧-ប្រាក់ប្រដាប់ក្តីត្រូវអនុវត្តតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សេចក្តីសម្រេចបញ្ចប់

១-ទទួលស្គាល់ឈ្មោះ [redacted]ចន្ថាវី ភេទស្រី កើតនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៨៣ មានទីកន្លែងកំណើត [redacted] ដែលមានឳពុកឈ្មោះ [redacted]ភាព និងម្តាយឈ្មោះ [redacted] សុខា និងឈ្មោះ [redacted] មួយគា ភេទស្រី ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៣ មានទីកន្លែងកំណើតស្ថិតនៅ [redacted] មានឳពុកឈ្មោះ[redacted]ភាព និងម្តាយឈ្មោះ [redacted] សុខា ជាមនុស្សតែម្នាក់ និងឱ្យប្រើប្រាស់ឈ្មោះ[redacted]មួយគា ភេទស្រី ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៣ មានទីកន្លែងកំណើត[redacted] ជាផ្លូវការ។

២-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

-ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ចៅក្រម**

ហត្ថលេខា និងត្រា: [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ.ចន្ទ..១១កើត.ខែ.ពិសាខ. ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

កណ្តាល ថ្ងៃទី.២០... ខែ.ឧសភា... ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រម**

[redacted]

Scanned with CamScanner